**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ផ្ទៃដីទំហំ ៦៧២ហិកតា ស្ថិតនៅភូមិវាលវង់ ឃុំរកាត ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងការធ្វើអនុបយោគផ្ទៃដីទំហំ ៥៥០ហិកតា ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋ ចំនួន ១៨៥គ្រួសារ ដែលទទួលរងផលប៉ះពាល់ផ្ទាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទំនប់ស្ទឹងពោធិ៍សាត់ លេខ៣ និងលេខ៥ នៅខេត្តពោធិ៍សាត់

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១ .-**

ត្រូវបានកាត់ផ្ទៃដីទំហំ ៦៧២ហិកតា (ប្រាំមួយរយចិតសិបពីរហិកតា) ស្ថិតនៅភូមិវាលវង់ ឃុំកោត ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ ដែលក្នុងនោះ ផ្ទៃដីទំហំ ៥៥០ហិកតា ប្រើប្រាស់សម្រាប់ធ្វើប្រទានកម្មជូនប្រជាពលរដ្ឋចំនួន ១៨៥គ្រួសារ និងផ្ទៃដីទំហំ ១២២ហិកតាទៀត ត្រូវរក្សាទុកជាដីសាធារណៈរបស់រដ្ឋ សម្រាប់ប្រើប្រាស់ជា៖ ទំនប់ផ្លូវទឹកទំហំ ២៥ហិកតា ដីភ្នំទំហំ ២ហិកតា និងដីសម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធទំហំ ៩៥ហិកតា។

ផ្ទៃដីទំហំ ៦៧២ហិកតានេះ មានបង្ហាញក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ដោយកំណត់តាមចំណុចគោលដែលមាននិយាមកានៃប្រព័ន្ធកូអរដោនេ UTM_ Zone 48N, WGS 1984 ដូចខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| 1 | 364779 | 1353502 | 22 | 368734 | 1352932 |
| 2 | 364919 | 1353461 | 23 | 368750 | 1352729 |
| 3 | 365016 | 1353390 | 24 | 368923 | 1352445 |
| 4 | 365419 | 1353360 | 25 | 368937 | 1352310 |
| 5 | 365617 | 1353420 | 26 | 368794 | 1352093 |
| 6 | 365790 | 1353728 | 27 | 368641 | 1352018 |
| 7 | 366515 | 1353814 | 28 | 368478 | 1351807 |
| 8 | 366514 | 1353953 | 29 | 368434 | 1351633 |
| 9 | 366697 | 1353809 | 30 | 368281 | 1351580 |
| 10 | 366771 | 1353606 | 31 | 368234 | 1351507 |
| 11 | 366937 | 1353550 | 32 | 368194 | 1351192 |
| 12 | 367326 | 1353550 | 33 | 368236 | 1350891 |
| 13 | 367622 | 1353569 | 34 | 368013 | 1351015 |
| 14 | 367974 | 1353643 | 35 | 367509 | 1351196 |
| 15 | 368307 | 1353846 | 36 | 366590 | 1351673 |
| 16 | 368345 | 1353971 | 37 | 365848 | 1352381 |
| 17 | 368390 | 1353966 | 38 | 365411 | 1352519 |
| 18 | 368369 | 1353929 | 39 | 365200 | 1352925 |
| 19 | 368343 | 1353641 | 40 | 365204 | 1353066 |
| 20 | 368414 | 1353306 | 41 | 364888 | 1353179 |
| 21 | 368561 | 1353080 | 42 | 364803 | 1353282 |



www.pheakdeylaw.com

**មាត្រា២.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ៥៥០ហិកតា (ប្រាំរយហាសិបហិកតា) ក្នុងទំហំផ្ទៃដីសរុបដែលកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ ដូចមានចែងក្នុងមាត្រា១ខាងលើ ពីដីសាធារណៈរបស់រដ្ឋ មកជាដីឯកជនរបស់រដ្ឋ។

**មាត្រា៣.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋ ដូចមានក្នុងមាត្រា២ខាងលើ ជូនអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋ សម្រាប់បែងចែកជូនប្រជាពលរដ្ឋ។

**មាត្រា៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងខ្លួនៗចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋាន គ.ស.ស.ជ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com

ផែនទីបង្ហាញទីតាំងសម្បទានដីសង្គមកិច្ចទំហំ ៦៧២ ហិកតា (ប្រាំមួយរយចិតសិបពីរ) ហិកតា

ស្ថិតនៅ ភូមិវាលវង់ ឃុំកោត ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់

ឧបសម្ព័ន្ធអនុក្រឹត្យលេខ៖[illegible]-បក ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៥



| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| 1 | 364779 | 1353502 | 22 | 368734 | 1352932 |
| 2 | 364919 | 1353461 | 23 | 368750 | 1352729 |
| 3 | 365016 | 1353390 | 24 | 368923 | 1352445 |
| 4 | 365419 | 1353360 | 25 | 368937 | 1352310 |
| 5 | 365617 | 1353420 | 26 | 368794 | 1352093 |
| 6 | 365790 | 1353728 | 27 | 368641 | 1352018 |
| 7 | 366515 | 1353814 | 28 | 368478 | 1351807 |
| 8 | 366514 | 1353953 | 29 | 368434 | 1351633 |
| 9 | 366697 | 1353809 | 30 | 368281 | 1351580 |
| 10 | 366771 | 1353606 | 31 | 368234 | 1351507 |
| 11 | 366937 | 1353550 | 32 | 368194 | 1351192 |
| 12 | 367326 | 1353550 | 33 | 368236 | 1350891 |
| 13 | 367622 | 1353569 | 34 | 368013 | 1351015 |
| 14 | 367974 | 1353643 | 35 | 367509 | 1351196 |
| 15 | 368307 | 1353846 | 36 | 366590 | 1351673 |
| 16 | 368345 | 1353971 | 37 | 365848 | 1352381 |
| 17 | 368390 | 1353966 | 38 | 365411 | 1352519 |
| 18 | 368369 | 1353929 | 39 | 365200 | 1352925 |
| 19 | 368343 | 1353641 | 40 | 365204 | 1353066 |
| 20 | 368414 | 1353306 | 41 | 364888 | 1353179 |
| 21 | 368561 | 1353080 | 42 | 364803 | 1353282 |




www.pheakdeylaw.com